# សំណួរដែលគេសួរជាញឹកញាប់

### 1. តើខ្ញុំអាចឆ្លងជំងឺរលាកថ្លើមប្រភេទ B ពីការចែករំលែកអាហារ និងភេសជ្ជៈ ឬឱបមនុស្សបានទេ

ទេ។ ជំងឺរលាកថ្លើមប្រភេទ B អាចឆ្លងតែតាមរយៈការរួមភេទ ការប៉ះពាល់ឈាមនឹងឈាម និងពីម្ដាយទៅទារកប៉ុណ្ណោះ។
ទំនាក់ទំនងធម្មតាដូចជាការឱប ការថើប និងការចែករំលែកអាហារ មិនមែនជាហានិភ័យចំពោះជំងឺរលាកថ្លើមប្រភេទ B នោះទេ។

### 2. ប្រសិនបើខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B តើខ្ញុំនឹងមានអារម្មណ៍ថាឈឺ ហើយមានស្បែកលឿងដែរឬទេ?

មនុស្សភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B មើលទៅ ហើយមានអារម្មណ៍សុខភាពល្អ។ វាមានសារសំខាន់ខ្លាំងណាស់ក្នុងការធ្វើតេស្តឈាម ប្រសិនបើអ្នកគិតថា អ្នកមានហានិភ័យនៃជំងឺរលាកថ្លើមប្រភេទ B។ នេះគឺជាវិធីតែមួយគត់ដើម្បីឱ្យដឹងថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬអត់។
ប្រសិនបើអ្នកមានរោគសញ្ញា នេះអាចរួមបញ្ចូល៖

- ការមានអារម្មណ៍អស់កម្លាំង។
- ការមានអារម្មណ៍ឈឺ និងមិនឃ្លាន។
- ការពិបាកផ្ដោតអារម្មណ៍

ស្បែក និងភ្នែកលឿងកើតឡើងតែពេលមនុស្សឈឺខ្លាំង ហើយធ្ងន់ធ្ងរខ្លាំងណាស់ប៉ុណ្ណោះ។

### 3. តើវាមានន័យដូចម្ដេចចំពោះនរណាម្នាក់ដែលជាអ្នកផ្ទុកជំងឺរលាកថ្លើមប្រភេទ B មានសុខភាពល្អ?

គឺថាមិនដែលមានអ្នកផ្ទុកជំងឺរលាកថ្លើមប្រភេទ B ដែលមានសុខភាពល្អនោះទេ ហើយពាក្យនេះគឺដូចជាហួសសម័យពេកហើយ។ ប្រសិនបើមនុស្សម្នាក់មានជំងឺរលាកថ្លើមប្រភេទ B នោះតែងតែមានហានិភ័យនៃការខូចខាតថ្លើម ហើយការត្រួតពិនិត្យជាប្រចាំជាមួយវេជ្ជបណ្ឌិត គឺមានសារសំខាន់។

LiverWELL
Incorporating HEPATITIS VICTORIA

GILEAD
Supported by a grant from Gilead Sciences